# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ

រាជធានីភ្នំពេញ, ថ្ងៃទី០៨...ខែមករា...ឆ្នាំ ២០១៤

លេខៈ..០១.ប្រ.ក........

## ប្រកាស
## ស្តីពីការអនុញ្ញាតច្បាប់
## ទៅបន្តការសិក្សានៅក្រៅប្រទេស

**រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ**

- បានឃើញ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រមលេខ នស/រកម/០១៩៦/០២ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ស្តីពីការបង្កើតក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- បានឃើញ អនុក្រឹត្យលេខ២៤ អនក្រ.បក ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- លិខិតកំណត់ទូតលេខ 2013/C/075 ចុះថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០១៣ របស់ស្ថានទូតណូវែលហ្សេឡង់ប្រចាំនៅទីក្រុងបាងកក។

## សម្រេច

**ប្រការ ១ ៖** ត្រូវបានអនុញ្ញាតឲ្យមន្ត្រីរាជការចំនួន០៣រូប ទៅចូលរួមវគ្គបណ្តុះបណ្តាលភាសាអង់គ្លេសទាក់ទងនឹង " Good Governance : Cross Cutting Issue " រយៈពេល០៦ខែ គិតចាប់ពីថ្ងៃទី២០ ខែមករា ដល់ថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០១៤ នៅទីក្រុងវែលីងតុន ប្រទេសណូវែលហ្សេឡង់ ដោយរក្សាទុកក្របខ័ណ្ឌ និងប្រាក់បៀវត្សជូនសាមីខ្លួន ដែលមានរាយនាមដូចខាងក្រោម ៖

| | | |
|---|---|---|
| ១. | លោក ជី រដ្ឋា | ប្រធានការិយាល័យនៃសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ |
| ២. | កញ្ញា លី ទ្រព្យល័ក្ខ | ប្រធានការិយាល័យនៃនាយកដ្ឋានបុរាណវិទ្យា និងបុរេប្រវត្តិវិទ្យា |
| ៣. | កញ្ញា កែវ នាទី | អនុប្រធានការិយាល័យនៃនាយកដ្ឋានសហប្រតិបត្តិការវប្បធម៌អន្តរជាតិ និងកិច្ចការអាស៊ាន |

**ប្រការ ២ ៖** នាយកខុទ្ទកាល័យ អធិការនៃអធិការដ្ឋាន ប្រធាននាយកដ្ឋានសវនកម្មផ្ទៃក្នុង អគ្គនាយករដ្ឋបាល និងហិរញ្ញវត្ថុ អគ្គនាយកបច្ចេកទេសវប្បធម៌ អគ្គនាយកបេតិកភណ្ឌ សាកលវិទ្យាធិការនៃសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ ប្រធាននាយកដ្ឋានបុរាណវិទ្យា និងបុរេប្រវត្តិវិទ្យា ប្រធាននាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងកិច្ចការអាស៊ាន ព្រមទាំងសាមីខ្លួនត្រូវមានភារកិច្ចអនុវត្តនូវប្រកាសនេះចាប់ពីថ្ងៃចុះហត្ថលេខាទៅ។

**រដ្ឋមន្ត្រី**

ភឿង-សកុណា

**ចម្លងជូន ៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងអប់រំយុវជន និងកីឡា
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ « ដើម្បីជូនជ្រាបជាព័ត៌មាន »
- ដូចប្រការ ២ « ដើម្បីអនុវត្ត »
- ឯកសារ-កាលប្បវត្តិ

ទូរស័ព្ទ / ទូរសា : 023 218 148 , E-mail : info@mcfa.gov.kh, www.mcfa.gov.kh, ប្រអប់សំបុត្រ 72
មហាវិថីព្រះនរោត្តម លេខ២២៧ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ